ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែសីហា ឆ្នាំ២០១៦



# មាតិកា


| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|
| I- | កិច្ចប្រជុំជំនាញបច្ចេកទេស | |
| | - សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ១-៣ |
| II- | កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៦ | ៤-១២ |
| III- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៦ | ១៣-១៤ |

# សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការបង្កើតសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុត គីមសាន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។



ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបង្កើតឡើងនៅឆ្នាំ២០០១ ក្នុងអណត្តិទី ២ នៃរាជរដ្ឋាភិបាល តាមព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៨៨ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស.) និងព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់បេសកកម្មឲ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីដឹកនាំសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើបញ្ហាដែលទាក់ទងដល់ការលើកម្ពស់ស្ថានភាព តួនាទីរបស់ស្ត្រី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា សំដៅកាត់បន្ថយឈានទៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភាព និងអំពើហឹង្សាលើស្ត្រី។ កន្លងមក ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានប្រើប្រាស់ស្លាកសញ្ញា LOGO របស់ក្រសួងកិច្ចការនារី។ តាមរយៈកិច្ចសាមញ្ញរបស់ ក.ជ.ក.ស. សមាជិក សមាជិកា បានផ្តល់យោបល់ថា គួរមានស្លាកសញ្ញាថ្មីដែលជាស្លាកសញ្ញារបស់ក.ជ.ក.ស. ដើម្បីប្រើប្រាស់ដោយឡែកជាផ្លូវការ។

ក.ជ.ក.ស.បានបើកិច្ចប្រជុំចំនួន ០៣ លើកស្តីពីស្លាកសញ្ញារបស់ ក.ជ.ក.ស. ដែលមានសមាសភាព

ចូលរួម សមាជិក សមាជិកា ក.ជ.ក.ស. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មកពី២៤ ក្រសួង ស្ថាប័ន ដើម្បីឆ្លងនិងសម្រេចលើស្លាកសញ្ញានេះ អង្គប្រជុំបានឯកភាពលើស្លាកសញ្ញារបស់ក.ជ.ក.ស.។

ការស្នើសុំប្រើប្រាស់ស្លាកសញ្ញានេះ មានគោលបំណងដាក់នៅកន្លែងធ្វើការ ពាក់នៅឯកសណ្ឋានមន្ត្រីរាជការក្របខណ្ឌ ក.ជ.ក.ស. ដាក់ក្បាលលិខិតផ្លូវការរបស់ ក.ជ.ក.ស. និងប្រើប្រាស់ជាផ្លូវការផ្សេងៗទៀត។

ស្លាកសញ្ញារបស់ ក.ជ.ក.ស. មានអត្ថន័យដូចខាងក្រោម៖

រូបស្ត្រី : តំណាងឲ្យស្ត្រីខ្មែរ ដែលតាមប្រវត្តិសាស្ត្រ ស្ត្រីខ្មែរធ្លាប់គ្រប់គ្រងប្រទេស ទាំងមូលដូចព្រះនាងលីវយីជាដើម។ រូបស្ត្រីបានគ្រងសម្លៀកបំពាក់បែបប្រពៃណី ដៃម្ខាងទ្រផែនដី ដែលមានរំលេចរូបផែនទីប្រទេសកម្ពុជា មានន័យថាគាំពារ ឬម្ខាងទៀតទប់ទល់លំនឹងផែនដី ក្នុងន័យថា រួមចំណែកការពារសន្តិភាព សុភមង្គលនិងសុខដុមរមនារបស់កម្ពុជា និងពិភពលោកឲ្យមាននិរន្តភាព។

រូបសម្បត្តិរបស់ស្ត្រីខ្មែរ : មានវង្ងង់មុខរាងដូចពងក្រពើ បង្ហាញពីភាពរមទម្យ រួសរាយ រាក់ទាក់ តែម៉ឹងម៉ាត់ ទម្រង់ភ្នែកមានលក្ខណៈដូចគ្រាប់ល្មុត បង្ហាញពីព្រហ្មវិហារធម៌ទាំង៤ គឺមេត្តា ករុណា ឧបេក្ខា និងមុទិតា ចិញ្ចើមកោងដូចដងធ្នូ បង្ហាញពីភាពឧស្សាហ៍ ផ្ចិតផ្ចង់ យកចិត្តទុកដាក់ បបូរមាត់ញញឹមមានល័ក្ខណ៍យល់ច្បាស់ពីកាតព្វកិច្ច ពាក់ម្កុដប្រកបដោយក្បាច់ត្របកឈូលទេស ប្រកាន់នូវអត្តសញ្ញាណជាតិជាស្ត្រីខ្មែរ។ ទឹកមុខស្ត្រីបង្ហាញនូវភាពឈ្លាសវៃ ស្លូតបូតសុភាពរាបសារ រួសរាយ មានអត្តចរិកម៉ឹងម៉ាត់ អំណត់អត់ធន់ តស៊ូពុះពារដោះស្រាយរាល់ការលំបាកស្មុគស្មាញចំពោះកិច្ចការគ្រួសារ និងកិច្ចការសង្គម ពោរពេញទៅដោយគំនិតច្នៃប្រឌិតខ្ពស់ ព្រមទាំងមានសីលធម៌ថ្លៃថ្នូរ រក្សាបាននូវវប្បធម៌ប្រពៃណីជាតិផូរផង់។ នៅលើត្រចៀកខាងស្តាំមានសៀតផ្ការំដួលដែលជានិមិត្តរូបរបស់ស្ត្រី ហើយតាមលក្ខណៈធម្មជាតិ ផ្ការំដួលមានក្លិន



ក្រអូបឈ្ងុយឈ្ងប់សុះសាយ តំណាងឲ្យកិត្តិយសកេរ្តិ៍ឈ្មោះរបស់ស្ត្រីខ្មែរពោរពេញទៅដោយចំណេះដឹង ដែលជាស្ត្រីខ្មែរជាដៃគូសំខាន់បំផុត និងមិនអាចខ្វះបានរបស់បុរសក្នុងការអភិវឌ្ឍប្រទេសជាតិ។

រូបផែនទីរបស់ប្រទេសកម្ពុជា : ដែលជាចំណែកមួយនៃផែនដីជាមួយនឹងប្រព័ន្ធទន្លេមេគង្គមានប្រភពនៅខ្ពង់រាបទីបេ និងមានរបបទឹកភ្លៀងទៀងទាត់ គឺរដូវទឹកឡើងពីខែមិថុនា ដល់ខែតុលា និងរដូវទឹកស្រកពីខែវិច្ឆិកា ដល់ខែឧសភា។ ទន្លេមេគង្គប្រៀបដូចជាព្រែកធំមួយសម្រាប់នាំទឹកទន្លេមេគង្គទៅចាក់ក្នុងបឹងទន្លេសាបក្នុងរដូវវស្សា និងហូរនាំទឹកត្រលប់មកកាន់ទន្លេមេគង្គវិញនៅរដូវប្រាំង ធ្វើឲ្យបឹងទន្លេសាបមានរាងដូចវិយូឡុងនៅរដូវប្រាំង ដោយសារភូមិសាស្ត្រអំណោយផលនេះ ធ្វើឲ្យប្រជាជនយើងងាយស្រួលប្រកបរបរកសិកម្ម និងមានត្រីហូបចុកគ្រប់គ្រាន់ ធ្វើឲ្យមានសុខភាពល្អ ប្រាជ្ញាវៃឆ្លាត និងមានពេលវេលាគ្រប់គ្រង ដើម្បីមានគំនិតធ្វើវត្ថុសិល្បៈផ្សេងៗពីតូចដល់ធំ និងសំណង់ស្ថាបត្យកម្ម បុរាណមហិមាទៀតផង។



ក្បាច់ផ្កាភ្ញី : មកលម្អស្ត្រី ព្រោះក្បាច់ផ្កាភ្ញីទេសនេះអាចវិវត្តខ្លួនមានផ្កា ផ្លែ ស្លឹក ធាង ដោយស្វ័យប្រវត្តិ ប្រដេញគ្នារហូត ក្បាច់ផ្កាភ្ញីទេសយកមកទ្រ និងអមស្ត្រី ព្រោះក្បាច់នេះមានធាតុញី និងឈ្មោលតាមរយៈនេះ បច្ចុប្បន្នការលើកស្ទួយ ឬជំរុញឲ្យក្លាយជាមេដឹកនាំទាំងបុរស និងស្ត្រី សាមគ្គីក្នុងនាមជាតិនិយម ទើបកម្ពុជាយើងមានឈ្មោះល្បីដូចអតីតកាល និងរីកចម្រើនអភិវឌ្ឍឥតឈប់ឈរ ដូចក្បាច់ផ្កាភ្ញីទេសវិវត្តិខ្លួនជានិរន្តរ៍(១)។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានស្នើឲ្យស្ថាប័នសាមីធ្វើការកែសម្រួលស្លាកសញ្ញាឡើងវិញ នឹងដាក់ប្រជុំម្តងទៀតនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

# II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៦*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ **ប្រចាំខែកក្កដា ឆ្នាំ២០១៦**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកក្កដាឆ្នាំ២០១៦សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣%ធៀបនឹងខែមុន និងកើនឡើង៣,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
|ម្ហូបអាហារ: | +៥,៨% | សាច់ជ្រូក: | +៣,៥% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១១,៦% | សាច់គោ: | +១០,៨% |
| សំលៀកបំពាក់ និងស្បែកជើង : | +៤,៧% | សាច់មាន់: | +៦,៥% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់ : | +៣,៥% | ត្រីស្រស់: | +៩,៥% |
| សុខាភិបាល | +៣,៦% | ផ្លែឈើ: | +៥,៨% |
| ភោជនីយដ្ឋាន: | +៤,៥% | បន្លែ: | +៨,១% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៤–២០១៦

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហាP | កញ្ញាP | តុលាP | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ៣,១% | ៣,១% | ៣,១% | | | |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥ | ០,២% | ០,៣% | ០,៤% | ០,២% | ០% | | | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៣,៩% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |

**P**: តួលេខខែសីហា កញ្ញា និងតុលា ឆ្នាំ២០១៦ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | កក្កដា២០១៦ | មិថុនា២០១៦ | កក្កដា២០១៥ | *ប្រភេទ* | កក្កដា២០១៦ | មិថុនា២០១៦ | កក្កដា២០១៥ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៩៧៛/១$ | ៤០៨៤៛/១$ | ៤១១៣៛/១$ | **បាត/ដុល្លារ** | ៣៤,៨៥បាត/១$ | ៣៥,១៤បាត/១$ | ៣៥,០៨បាត/១$ |
| **៛/បាត** | ១១៨៛/១បាត | ១១៦៛/១បាត | ១១៧៛/១បាត | **ដុង/ដុល្លារ** | ២២២៧៨ដុង/១$ | ២២២៥៨ដុង/១$ | ២១៨១១ដុង/១$ |
| **៛/ដុង** | ០,១៨៤៛/១ដុង | ០,១៨៣៛/១ដុង | ០,១៨៩៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកក្កដាឆ្នាំ ២០១៦ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១១៧៥,៧ប៊ីលានរៀល( *មធ្យមប្រចាំខែ ១០៧% នៃផែនការ*) ក្នុងនោះ: ចំណូលចរន្តចំនួន១១៤៣,០ប៊ីលានរៀល( *មធ្យមប្រចាំខែ ១០៩% នៃផែនការ*) និងចំណូលមូលធនចំនួន៣២,៨ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង០,២% និង កើនឡើង៨,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៩៨៦,៣ប៊ីលានរៀល ថយចុះ៤,៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១០,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៤–២០១៦ (ប៊ីលានរៀល)



✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៥៦,៧ប៊ីលានរៀល កើនឡើង១៩,៣% ធៀបនឹងខែមុន និងកើនឡើង៧១,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +១,១% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១០,៩%) | ➢កាស៊ីណូ: +១៤,៤% | (-២០,១%) |
| ➢ *ចំណូលពន្ធដារ:*+៤,៩% (អគ្គនាយកដ្ឋានពន្ធដារ) | (+២៤,៦%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +១៤៧,៩% | (-២០,១%) |
| | | ➢ នេសាទ:-៩៦,៥% | (-៩៦,៣%) |
| | | ➢សម្បទានរ៉ែ: +២៦,៦% | (+៧២,៨%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៧២,៥% | (+១៣៣,៥%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -៣៣,៧% | (+៤៥%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +០,៦% | (-១៩,២%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១០៤២,៤ប៊ីលានរៀល(*មធ្យមប្រចាំខែ ៧១% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន៧៩៣,៥ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៧៣% នៃផែនការ*) និងចំណាយមូលធនមានចំនួន ២៤៨,៩ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង១៩,១%ធៀបនឹងខែមុននិងកើនឡើង១,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ០,៣%ធៀបនឹងខែមុននិងថយចុះ៩,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានអតិរេកចំនួន **១៣៣,៣** ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៤–២០១៦
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដាឆ្នាំ២០១៦មានលក្ខណ:ដូចខាងក្រោម៖

➢ រូបិយវត្ថុ $M_2$ មានចំនួន៥៥៦០៩ប៊ីលានរៀល កើនឡើង២%ធៀបនឹងខែមុន និងកើនឡើង២០,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើង $M_2$ ក្នុងខែនេះ ជារួម បណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ១,៤% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៦,៥% និងប្រាក់បញ្ញើជារូបិយបណ្ណ ២,០%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកក្កដាឆ្នាំ២០១៦



➤ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៩% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,១% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៦

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៦% | ១៥,៩% | ១៥,៨% | ១៥,៧% | ១៥,៩% | ១៥,៩% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១២,២% | ១២,១% | ១១,៩% | ១១,៦% | ១១,២% | ១១,៣% | ១១,២% | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកក្កដា២០១៦: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




---

➤ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៨២១៣ ប៊ីលានរៀលកើនឡើង ៥,២%ធៀបនឹងខែមុន និងកើនឡើង៣១,០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៥៨២៨លានដុល្លារ កើនឡើង១,៧%ធៀបនឹងខែមុន និងកើនឡើង២៩,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កក្កដា២០១៦* | *មិថុនា២០១៦* | *កក្កដា២០១៥* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ៥៥៣៤៩ | ៥៤៣៥២<br>៨០៣ | ៤៥១៩៤<br>៥៤៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១១៣០៣ | ១០៤៥៩ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៨១% | ៦,៧៩% | ៦,៧៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៧,៣៥% | ១៧,៣៤% | ១៦,២៣% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៥៥% | ៤,៥២% | ៤,៣៨% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១២,១១% | ១១,៧៤% | ១១,៥៤% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែកក្កដាឆ្នាំ២០១៦ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➤**កសិកម្ម**:

✓នេសាទសម្រេចបាន៦៣,៧ពាន់តោនកើនឡើង១៣%ធៀបនឹងខែមុន និងកើនឡើង២២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

### ➢រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥៤៥,៣GWHមានការថយចុះ៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៣៦៩,៩២GWHមានការកើនឡើង៧៤%ធៀបនឹងខែមុន និងកើនឡើង៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១១១,២១៣GWHមានការថយចុះ៥៧%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

### ➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៦៦២,៨លានដុល្លារមានការកើនឡើង១០%ធៀបនឹងខែមុន និងកើនឡើង១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន—កក្កដា២០១៦ | ចំនួន—មិថុនា២០១៦ | ចំនួន—កក្កដា២០១៥ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១២ | ១៦ | ៩ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៣០ | ១៥២០ | ១៣៨៣ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | ១៣ | ៤៨ | ៣៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣០ | ៤៣ | ១៥ |

### ➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៦៣៥,៧ពាន់ម៉ែត្រការ៉េ កើនឡើង៨%ធៀបនឹងខែមុន និងកើនឡើង១៤០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង២៧៥,២លានដុល្លារកើនឡើង១៤%ធៀបនឹងខែមុន និងកើនឡើង២០១%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^2$—កក្កដា២០១៦ | ពាន់ម$^2$—មិថុនា២០១៦ | ពាន់ម$^2$—កក្កដា២០១៥ |
|---|---|---|---|
| ▪ លំនៅឋាន | ៣៨៤,២ | ២៨៩,៤ | ៩២,១ |
| ▪ ឧស្សាហកម្ម | ៦៣,២ | ១៩៣,៩ | ៨៦,៦ |
| ▪ពាណិជ្ជកម្ម | ១០១,៤ | ៦២,៨ | ១២,៣ |
| ▪ ទេសចរណ៍ | ៦៨,៧ | ២១,៧ | ៦៩,០ |
| ▪ផ្សេងៗ | ០,៧ | ០,០ | ០,០ |
| អនុញ្ញាតសរុប | ៦៣៥,៧ | ៥៨៦,៣ | ២៦៤,៥ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៦០,៤% និងពាណិជ្ជកម្ម១៥,៩% នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–កក្កដា ២០១៦ | នាក់–មិថុនា ២០១៦ | នាក់–កក្កដា ២០១៥ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៦៧៣ | ១៣០៤ | ៦០៤ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារនិងក្រុមហ៊ុន | ១១៥៣២ | ១១៩៧៧ | ១២៦៧៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩១១៧ | ៨៧៧៩ | ៩៤៥៧ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៤១៥ | ៣១៩៨ | ៣២១៦ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កក្កដា២០១៦ | មិថុនា២០១៦ | កក្កដា២០១៥ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៨៥៨,៤ | ៥៧,៩ | ២៣៦,២ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៦៧,៨ | ១៦,៤ | ៧៦,៨ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៦៥,១ (២៥,៤) | ២២,៥ (២,១) | ៨៩,៧ (១) |
| វិស័យទេសចរណ៍ | ៦៧៩,៨ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៤៥,៧ | ១៩ | ៦៩,៧ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២០ | ១៣ | ២៣ |
| បង្កើតការងារ (ពាន់នាក់) | ១៥ | ៨ | ៣០,៦ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន–កក្កដា ២០១៦ | ចំនួន–មិថុនា ២០១៦ | ចំនួន–កក្កដា ២០១៥ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | | ៤១២ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | | ១១ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៤០៨ | ៤១០ | ១២៦ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៦៧៧,១ពាន់តោនថយចុះ៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+១៦% | (+២៩%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+៨៧% | (-៤២%) |
| ▪ កំពង់ផែកំពង់សោម:-២៥% | (-១៤%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +១៤៤% | (+១០៨%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៥,៧ | ១% | ១៤% |
| ក្នុងនោះទទួល | ២,៣ | ៦% | 0% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៨៧,១ | ៣% | -៩% |
| ក្នុងនោះទទួល | ៤៤,៤ | -២% | 0% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៨០៩.២ | -១% | -២១% |
| ក្នុងនោះហៅចូល | ៨៥១,១ | ១% | -២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៩៧៧៥,៤ | ១១% | -២២% |
| ក្នុងនោះហៅចូល | ៩៦៧៧,១ | ១១% | -២២% |

## ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៤ | ៤៤% | ១៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣១ | ៣0% | -៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៧៨,៣ | ២0% | ១១% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |



## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកក្កដាមានចំនួន ៤៤៨៥,៧ប៊ីលានរៀល (ស្មើនឹង ១១២១,៤លានដុល្លារ ស.រ.អា.)ថយចុះ១,៦%ធៀបនឹងខែមុន និងថយចុះ២,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២,៧% | -១,៤% | រថយន្តសរុប (ប៊ី.ល.រ) | -០,៥% | -២,៤% |
| ប្រេងម៉ាស៊ូត | -១៦,១% | +១៩,៥% | រថយន្តសរុប (គ្រឿង) | -៥% | +១០,២% |
| ឧស្ម័ន | +៣,៧% | -៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -១៣,៣% | -២៩,៧% |
| អគ្គិសនីនាំចូល | -៤៥,០% | +៩,០% | ម៉ូតូ (គ្រឿង) | +៣២,៧% | -៨,១% |
| ដែកសំណង់ | +៦៦,៨% | +៨០,៤% | អង្ករ | +៤៦,៦% | -៧៣,៨% |
| ស៊ីម៉ង់ត៍ | -១០,២% | -៤០,៤% | ផ្លែឈើនិងបន្លែ | +៦,១% | -១៩,២% |
| គ្រឿងអេឡិចត្រូនិក | -៥៧,០% | +៤០,៨% | ជីនិងថ្នាំកសិកម្ម | +២៦,២% | +១៥១,៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | -១៣,១% | +៦% |

➡ **ការនាំចេញ** ខែកក្កដាឆ្នាំ២០១៦ មានចំនួន**៤៥១៧**ប៊ីលានរៀល ស្មើនឹង**១១២៩,២**លានដុល្លារ ស.រ.អា.(**១០០,៧**% នៃការនាំចូល)កើនឡើង១៦,៩%ធៀបនឹងខែមុន និងកើនឡើង១០,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -១៦,៤% | -៩០,៨% | ផលិតផលនេសាទ | -៥១,១% | -៤៥,៣% |
| វាយនភណ្ឌនិងស្បែកជើង | +២៧,៤% | +១២,២% | កៅស៊ូ | +៣៥,១% | +១៤,៣% |
| អង្ករ | -១៨,៩% | -១៩,៦% | | | |

➡ក្នុងខែកក្កដានេះជញ្ជីងពាណិជ្ជកម្មមានអតិរេកចំនួន ៣១,៣ប៊ីលានរៀលស្មើនឹង៧,៨លានដុល្លារ ស.រ.អា.។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដាឆ្នាំ២០១៦នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +០,១% | +១០,៨% | — |
| ២ | ថ្លៃត្រីស្រស់ | +០,៧% | +៩,៥% | — |
| ៣ | ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | -៧៣% | -៦៦% | — |
| ៤ | ការនាំចេញអង្ករ | -១៩% | -២០% | ការនាំចេញថយចុះ៨% បើប្រៀបធៀប៧ខែ ឆ្នាំ២០១៦និង២០១៥ |

## ៧) សេចក្តីសន្និដ្ឋាន

១) ថ្លៃទំនិញនៃក្រុមម្ហូបអាហារមានការឡើងថ្លៃខ្ពស់ (៥,៨%) ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ គួរឲ្យកត់សម្គាល់គឺ ថ្លៃសាច់គោ ត្រីស្រស់ និងបន្លែ។ ការឡើងថ្លៃខ្ពស់នៃទំនិញប្រើប្រាស់ ជាពិសេសម្ហូបអាហារ ធ្វើឲ្យបន្ទុកចំណាយដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែខ្ពស់ និងជាសម្ពាធលើស្ថិរភាពនិងសន្តិសុខសង្គម។

២) ចរិកាឆ្លងកាត់រថនាគាររាជធានី-ខេត្ត មានការថយចុះគួរឲ្យកត់សម្គាល់ ជាចម្បងដោយសារចំណូលពន្ធប្រថាប់ត្រាថយចុះ ព្រោះមានការលើកលែងពន្ធផ្ទេរមរតក។

៣) តួលេខទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. ក្នុងខែនេះមានការស្ទុះឡើងដោយសារ គម្រោងអភិវឌ្ឍន៍ឧទ្យានជាតិនៅខេត្តកំពង់ស្ពឺ គម្រោងសំណង់សណ្ឋាគារផ្កាយប្រាំ ក្លឹបវាយកូនហ្គោល និងសំណង់ក្រុមហ៊ុនប៊ូយ៉ុងនៅខេត្តសៀមរាប។

៤) ក្នុងខែកក្កដាឆ្នាំ២០១៦នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមានសញ្ញាវិជ្ជមានដែលជាករណីកម្រ។ មូលហេតុអាចដោយសារ កត្តារដូវកាល និងមានផលិតកម្មជំនួសការនាំចូលមួយចំនួន ដូចជាស៊ីម៉ង់និងភេសជ្ជៈជាដើម៕

## III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៨/១៦ **ម៉ោង០៩:០០នាទី** | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី២ លើស្ថានភាពអគ្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន វីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៥-០៦-០៧ /០៨/១៦ **ម៉ោង០៩:៣០នាទី** | ដឹកនាំគណៈកម្មការចុះត្រួតពិនិត្យលើការសាងសង់ Control tower, Taxiway និងការងារផ្សេងៗទៀតរបស់អាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប នៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប។ |
| ៣ | ០៩/០៨/១៦ **ម៉ោង០៩:០០នាទី** | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី៣ លើស្ថានភាពអគ្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន វីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៦/០៨/១៦ **ម៉ោង០៧:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធនៅមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពខេត្តតាកែវ។ |
| ៥ | ១៧/០៨/១៦ **ម៉ោង០៩:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **សយ សុខាន់** និង CAO នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៨/០៨/១៦ **ម៉ោង០៩:០០នាទី** | បន្តដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើកទី៤ លើស្ថានភាពអគ្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន វីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៩/០៨/១៦ **ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំបូកសរុបចុងក្រោយរបស់គណៈកម្មការអន្តរក្រសួង និងក្រុមការងារបច្ចេកទេសដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យនៅជាប់របងជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីពិនិត្យ និងពិភាក្សាលើសំណូមពររបស់ប្រជាពលរដ្ឋ និងរបាយការណ៍ជូនរាជរដ្ឋាភិបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **២២/០៨/១៦ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងវេទិកាស្តីពី "ការការពារ និងអភិរក្សធនធានធម្មជាតិ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | **២៥/០៨/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកក្កដា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **២៩/០៨/១៦ ម៉ោង១៧:០០នាទី** | ជួបប្រជុំពិភាក្សាការងារអំពីការសាងសង់ក្លោងទ្វារ "A" នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាមួយលោក **លី រស្មី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **៣០/០៨/១៦ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **៣១/០៨/១៦ ម៉ោង១៤:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីផែនការសកម្មភាពត្រៀមរៀបចំការងារសម្រាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំអាណត្តិទី៤ ឆ្នាំ២០១៧ នៅស្រុកព្រែកប្បាស។ |



រូបភាពក្នុងកិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
ប្រចាំខែកក្កដា ឆ្នាំ២០១៦



# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in